ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបង្ហាញ
# ស្តីពី
# ការអនុវត្តការប្រមូលពន្ធលើចំណេញមូលធន
# របស់ប្រទេសមួយចំនួន និងករណីកម្ពុជា

នាយកដ្ឋានពន្ធចលនទ្រព្យ និងអចលនទ្រព្យ

នៃអគ្គនាយកដ្ឋានពន្ធដារ




# មាតិកា

- សង្ខេប CGT ប្រទេសមួយចំនួន
- សង្ខេប CGT នៅកម្ពុជា
- បញ្ហាប្រឈមនៃការប្រមូល CGT
- ផែនការផ្សព្វផ្សាយរបស់ អពជ
- អត្ថប្រយោជន៍នៃការប្រមូលពន្ធលើចំណេញមូលធន




# ប្រទេសស៊ុយអ៊ែត



| អត្រាពន្ធចំណេញមូលធន | ឆ្នាំអនុវត្ត | ការលើកលែង |
|---|---|---|
| • **៣០%** នៃចំណេញមូលធនចំពោះរូបវន្តបុគ្គល<br>• **២១,៤%** នៃចំណេញមូលធនចំពោះនីតិបុគ្គល | ១៩១០ | • ការលើកលែងពន្ធសម្រាប់អង្គភាពសាជីវកម្មស៊ុយអ៊ែតពីចំណេញទាក់ទងនឹងការលក់ឬផ្ទេរភាគហ៊ុនសម្រាប់គោលបំណងពាណិជ្ជកម្ម។<br>• លើកលែងភាគហ៊ុនដែលបានកាន់កាប់ក្នុងរយៈពេលយ៉ាងហោចណាស់មួយឆ្នាំ។ |




# ប្រទេសអូស្ត្រាលី



| អត្រាពន្ធចំណេញមូលធន | ឆ្នាំអនុវត្ត | ការលើកលែង |
|---|---|---|
| ជាប់ពន្ធតាមអត្រាពន្ធប្រាក់ចំណូលរូបវន្តបុគ្គល (0-៤៥%) | ១៩៨៥ | • និវាសនដ្ឋានជាគោលដើម<br>• ទោចក្រយានយន្ត និងរថយន្ត<br>• ទ្រព្យសកម្មប្រើប្រាស់សម្រាប់គោលដៅអាជីវកម្មដែលអ្នកជាប់ពន្ធបានធ្វើការរំលស់រួចហើយ<br>• ទ្រព្យប្រើប្រាស់ផ្ទាល់ខ្លួនមានតម្លៃ តិចជាង AUD 10 000 (ប្រមាណ ៧ ៣០០ ដុល្លារអាមេរិក) ។ល។ |




# ប្រទេសកូរ៉េខាងត្បូង

| អត្រាពន្ធចំណេញមូលធន | ឆ្នាំអនុវត្ត | ការលើកលែង |
| --- | --- | --- |
| • **៦%-៣៨%** (បើរយៈពេលកាន់កាប់ > ២ឆ្នាំ)<br>• **៤០%** (បើរយៈពេលកាន់កាប់ ១-២ឆ្នាំ)<br>• **៥០%** (បើរយៈពេលកាន់កាប់ < ១ឆ្នាំ) | ១៩៦០ | • ការលក់អចលនទ្រព្យ ដែលបានបញ្ជាក់ពីសាលក្រមបញ្ជាក់ថាក្ស័យធន<br>• ចំណេញមូលធនពីការលក់ដីកសិកម្ម ដែលបានធ្វើរយៈពេលយ៉ាងហោចណាស់ ៨ឆ្នាំ<br>• ចំណេញមូលធនរបស់កសិករពីការលក់ដីស្រែ ដើម្បីទិញដីស្រែផ្សេង |




# ប្រទេសម៉ាឡេស៊ី



| អត្រាពន្ធចំណេញមូលធន | ឆ្នាំអនុវត្ត | ការលើកលែង |
|---|---|---|
| ៣០ % នៃចំណេញមូលធន | ១៩៩៥ | • រូបវន្តបុគ្គលត្រូវបានផ្តល់ការអនុគ្រោះ ឱ្យដកពីចំណេញមូលធនជាប់ពន្ធ នូវទឹកប្រាក់ ១០ ០០០ រីងហ្គីត (ប្រមាណជិត ១០ លានរៀល) ឬ ដក ១០% ពីចំណេញមូលធន (យកជម្រើសណា ដែលខ្ពស់ជាង)។<br>• រូបវន្តបុគ្គលដែលមានសញ្ជាតិម៉ាឡេស៊ី ឬជានិវាសនជនអចិន្ត្រៃយ៍ ត្រូវបានលើកលែងតែម្តងគត់ក្នុងមួយជីវិត ចំពោះចំណេញមូលធនសម្រេចបានពីការផ្ទេរនិវាសនដ្ឋានឯកជន របស់គាត់។<br>• ការលើកលែងពន្ធចំពោះប្រតិបត្តិការដូចជា៖ ការផ្ទេររវាងប្តី ប្រពន្ធ/ឪពុកម្តាយ និងកូនបង្កើត/យាយតា និងចៅបង្កើត, អំណោយជូនរដ្ឋ ឬអាជ្ញាធរដែនដី ឬសប្បុរសធម៌ ជាដើម។<br>• ការផ្ទេរអចលនទ្រព្យដែលមានតម្លៃ ទាបជាង ២០០ ០០០ រីងហ្គីត (ប្រមាណជិត ២០០ លានរៀល) *(ទើប អនុវត្តចាប់ពីឆ្នាំ២០១៩ ដោយ ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩)* |




# ប្រទេសហ្វីលីពីន



| អត្រាពន្ធចំណេញមូលធន | ឆ្នាំអនុវត្ត | ការលើកលែង |
|---|---|---|
| • **អចលនទ្រព្យ៖ ៦%** នៃថ្លៃលក់សរុប ឬតម្លៃទីផ្សារដែលសមរម្យ (តម្លៃមួយណាដែលខ្ពស់ជាង)<br>• **ភាគហ៊ុន (ដែលមិនជួញដូរក្នុងទីផ្សារភាគហ៊ុន)៖**<br>**-១៥ %** ចំពោះសហគ្រាសក្នុងស្រុក<br>**-៥ % និង ១០ %** ចំពោះសហគ្រាសក្រៅស្រុក<br>• **មូលបត្រ៖ ០.៦ %** គិតលើថ្លៃជួញដូរមូលបត្រ<br>• **ចំណេញមូលធនសហគ្រាស៖ ៣២ %**<br>(ក្របខណ្ឌពន្ធលើប្រាក់ចំណូល) | ប្រហែល ៣ ទសវត្ស (ឆ្នាំ ១៩៩៤ តួលេខចំណូលឆ្នាំដំបូងគេពី IMF) | ចំណេញមូលធនពីការលក់មូលបត្របំណុល ការធានា ឬវិញ្ញាបនប័ត្រ ផ្សេងទៀតនៃបំណុលដែលមានកាលកំណត់លើសពីប្រាំឆ្នាំ។ |




# ប្រទេសថៃ



| អត្រាពន្ធចំណេញមូលធន | ឆ្នាំអនុវត្ត | ការលើកលែង |
|---|---|---|
| • រូបវន្តបុគ្គលជាផ្នែកមួយនៃពន្ធលើប្រាក់ចំណូលរូបវន្តបុគ្គល (៥% - ៣៥%)<br>• នីតិបុគ្គលអនិវាសនជន ១៥%<br>• នីតិបុគ្គលនិវាសនជន ២០% | N/A | • អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរដ្ឋ<br>• អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់ សហគមន៍ ឬបុគ្គលណាដែលត្រូវបានរៀបចំឡើង និង ដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរធម៌ ដែលមិនមានគោលដៅស្វែងរកប្រាក់ចំណេញ<br>• អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស<br>• និវាសនដ្ឋានស្នាក់នៅជាគោលដើម ដែលរូបវន្តបុគ្គលបានស្នាក់នៅក្នុងរយៈពេលជាប់ៗគ្នាយ៉ាងតិចបំផុត ៥ឆ្នាំ មុនការសម្រេចបានចំណេញមូលធន និងមានការបញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់ជាធរមានពីអាជ្ញាធរដែនដី ឬអាជ្ញាធរពាក់ព័ន្ធ<br>• អចលនទ្រព្យដែលមានរយៈពេលកាន់កាប់ លើសពី ៥០ឆ្នាំ។ |




# ប្រទេសវៀតណាម

| អត្រាពន្ធចំណេញមូលធន | ឆ្នាំអនុវត្ត | ការលើកលែង |
|---|---|---|
| • ២% លើតម្លៃលក់ជាក់ស្តែងនៃអចលនទ្រព្យ (រូបវន្តបុគ្គល)<br>• ២០% លើប្រាក់ចំណេញមូលធនសម្រេចបានពីការលក់ភាគហ៊ុន (រូបវន្តបុគ្គល)<br>• ២០% លើប្រាក់ចំណេញ (សម្រាប់ក្រុមហ៊ុន) | N/A | -ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ក្នុងរង្វង់ញាតិ<br>-ការផ្ទេរកម្មសិទ្ធិនិវាសនដ្ឋានអចិន្ត្រៃយ៍<br>-អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់បេសកកម្មការទូត ឬកុងស៊ុលបរទេស<br>-ការផ្ទេរសិទ្ធិដែលជាអំណោយមិនឱ្យលើសពី ១០ លានដុង (ប្រហែលជា ៤៣០ ដុល្លារ) |




DK DANEMARK 42%
FI: FINDLAND 34%
IE: IRELAND 33%
NO: NORWAY 31.68%
SE: SWEDEN 30%
NL: NETHERLANDS 30%
FR: FRANCE 30%
DE: GERMANY 26.375%
IT: ITALY 26%
IS: ICELAND 22%
EE: ESTONIA 20%
LV: LATVIA 20%
GB: GREAT BRITAIN 20%
PL: POLAND 19%




# ការដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធន នៅកម្ពុជា

ផ្អែកលើការសិក្សាបទពិសោធន៍ពីបណ្តាប្រទេសនានា និងស្ថានភាពសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ពន្ធលើចំណេញមូលធនត្រូវបានរៀបចំអនុវត្តដោយកំណត់ជាគោលការណ៍ ដូចខាងក្រោម÷

- **អត្រាពន្ធ÷** កម្ពុជាកំណត់យកអត្រាថេរ ២០% ទៅលើផលចំណេញសម្រេចបាន ពុំមែនយក ២០% នៃតម្លៃលក់នោះទេ ដែលនេះជាអត្រាមធ្យមបើប្រៀបធៀបនឹងបណ្តាប្រទេសដែលយើងបានធ្វើការសិក្សា។

- **ការកំណត់ថ្លៃដើម÷**សម្រាប់អចលនទ្រព្យ ករណីអ្នកជាប់ពន្ធ ពុំមានឯកសារអំពីបន្ទុកចំណាយ កម្ពុជាអនុញ្ញាតឱ្យកាត់ថ្លៃដើមស្មើនឹង៨០%នៃថ្លៃលក់)។ ខុសពី ករណីប្រទេសមួយចំនួនដែលកំណត់យកពន្ធលើថ្លៃលក់ តែម្តងដោយពុំគិតពីការខាត ឬចំណេញរបស់អ្នកជាប់ពន្ធនោះទេ ដូចជាករណី ហ្វីលីពីន ៦% នៃតម្លៃលក់ ឬតម្លៃទីផ្សារតាមការកំណត់របស់រដ្ឋបាលសារពើពន្ធ




# ការដាក់ឱ្យអនុវត្តពន្ធលើចំណេញមូលធន នៅកម្ពុជា

- **ការលើកលែងពន្ធ÷** មានចំណុចជាច្រើនដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងបណ្ដាប្រទេសជិតខាងដែរ ជាពិសេសចំពោះអចលនទ្រព្យ យើងបានគិតគូរឱ្យមានសង្គតិភាពគ្នាជាមួយនឹងការអនុវត្តពន្ធប្រថាប់ត្រា។




# ប្រទេសកម្ពុជា



**មូលធន ឬទ្រព្យ** ដែលជាកម្មវត្ថុជាប់ **ពន្ធលើចំណេញមូលធន**មាន **០៦** ប្រភេទគឺ÷


អចលនទ្រព្យ


ភតិសន្យា


ទ្រព្យវិនិយោគ



កេរ្តិ៍ឈ្មោះអាជីវកម្ម


កម្មសិទ្ធិបញ្ញា


រូបិយវត្ថុបរទេស




# កម្មវត្ថុនៃការកំណត់ពន្ធ

អ្នកជាប់ពន្ធសម្រេចបានចំណេញមូលធននៅពេល÷

1. លក់ឬផ្ទេរ ឬបង្កើតឱ្យមានសិទ្ធិគ្រប់គ្រងលើទ្រព្យ ឬ
2. ចុះបញ្ជីសម្រាប់ការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់ទ្រព្យនៅអាជ្ញាធរមានសមត្ថកិច្ច ឬ
3. ពេលសម្រេចផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ទ្រព្យដោយសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។




# អត្រាពន្ធ និងមូលដ្ឋានគិតពន្ធ

**អត្រាពន្ធ:** ត្រូវកំណត់ដោយអត្រាថេរ ២០%

**មូលដ្ឋានគិតពន្ធ** គឺជា **ចំណេញមូលធន** ដែលជាប្រាក់ចំណូលជាប់ពន្ធបានពីការយកចំណូលពីការលក់ ឬផ្ទេរមូលធន ដកការកាត់កងចំណាយដែលអនុញ្ញាតឬថ្លៃដើមនៃទ្រព្យ។

ចំណេញមូលធន = ថ្លៃលក់ឬផ្ទេរនៃទ្រព្យ − ថ្លៃដើមនៃទ្រព្យ

- ថ្លៃលក់ឬផ្ទេរនៃទ្រព្យ ↓ តម្លៃកំណត់ក្នុងកិច្ចសន្យា ឬឯកសារពាក់ព័ន្ធ
- ថ្លៃដើមនៃទ្រព្យ ↓ ថ្លៃដើមពេលទិញទ្រព្យ និងចំណាយពាក់ព័ន្ធ




# ថ្លៃដើមនៃទ្រព្យ

**ថ្លៃដើមនៃទ្រព្យ** សំដៅដល់ថ្លៃដើមពេលទិញឬទទួលទ្រព្យ និងចំណាយពាក់ព័ន្ធដូចមានលម្អិតខាងក្រោម÷

| | |
|---|---|
| ថ្លៃដើមពេលទិញ ឬទទួលទ្រព្យ | ចំណាយកម្រៃជើងសា |
| ចំណាយលើសេវាពិគ្រោះយោបល់ | ចំណាយលើការវាយតម្លៃទ្រព្យ |
| ប្រាក់ពន្ធប្រថាប់ត្រាដែលបានបង់ពេលទិញឬទទួលទ្រព្យ | ចំណាយលើសេវារដ្ឋបាលលើការខ្ចីប្រាក់ដើម្បីទិញឬទទួលទ្រព្យ |
| ប្រាក់ពន្ធអចលនទ្រព្យឬពន្ធលើដីធ្លីមិនបានប្រើប្រាស់ដែលបានបង់ | ចំណាយការប្រាក់ដែលបានបង់ក្នុងអំឡុងពេលកាន់កាប់ទ្រព្យ |
| ចំណាយលើសេវារដ្ឋបាលសុរិយោដីឬភូមិបាល | ចំណាយថែទាំនិងកែលម្អទ្រព្យ |
| ចំណាយលើការផ្សព្វផ្សាយពាណិជ្ជកម្ម | ចំណាយក្នុងការបង្កើតឬរក្សាការពារនូវសិទ្ធិកាន់កាប់ទ្រព្យ |




# វិធាននៃការកាត់កងចំណាយ

- វិធាននៃការកាត់កងចំណាយត្រូវកំណត់៖
  - មូលធនជា **អចលនទ្រព្យ**៖ ជ្រើសរើសវិធីណាមួយដូចខាងក្រោម
    - **ក. វិធីកាត់កងចំណាយតាមការកំណត់** (៨០%នៃចំណូលពីការលក់ឬផ្ទេរទ្រព្យ)
    - **ខ. វិធីកាត់កងចំណាយជាក់ស្តែង**
  - មូលធន **ដទៃទៀត**៖អនុញ្ញាតឱ្យ**កាត់កងតាមចំណាយជាក់ស្តែង** ប៉ុណ្ណោះ
- ករណីចំណាយជាក់ស្តែង មានចំនួនច្រើនជាងចំណូលពីការលក់ឬផ្ទេរទ្រព្យ (ករណីខាត) នោះអ្នកជាប់ពន្ធពុំមានកាតព្វកិច្ចបង់ពន្ធលើចំណេញមូលធនទេ។

# ការគណនាពន្ធលើចំណេញមូលធន

ពន្ធលើចំណេញមូលធន = មូលដ្ឋានគិតពន្ធ × អត្រាពន្ធ

មូលដ្ឋានគិតពន្ធ → ចំណេញមូលធន

អត្រាពន្ធ → ២0%




## ឧទាហរណ៍ (ចំណាយតាមការកំណត់)

លោក **ក** លក់ផ្ទះទៅឱ្យលោក **ខ** ក្នុងតម្លៃ **៨០០ លានរៀល** ដោយមិនបានរក្សាឯកសារចំណាយនានា។ ដូចនេះលោក **ក** ជ្រើសរើសវិធីកាត់កងចំណាយតាមការកំណត់ ដើម្បីគណនាពន្ធលើចំណូលមូលធន។

| | |
|---|---|
| ➢ **គណនាថ្លៃដើមនៃទ្រព្យ** | **ថ្លៃលក់ឬផ្ទេរនៃទ្រព្យ x ៨០%** |
| | 800 លាន x 80% = 640 លានរៀល |
| ➢ **គណនាចំណេញមូលធន** | **ថ្លៃលក់ឬផ្ទេរនៃទ្រព្យ - ថ្លៃដើមនៃទ្រព្យ** |
| | 800 លាន - 640 លាន= 160 លានរៀល |
| ➢ **គណនាពន្ធលើចំណេញមូលធន** | **ចំណេញមូលធន X ២០%** |
| | 160 លាន x 20%= 32 លានរៀល |




## ឧទាហរណ៍ (ចំណាយជាក់ស្តែង)

លោក **ក** លក់ផ្ទះទៅឱ្យលោក **ខ** ក្នុងតម្លៃ **៦០០ លានរៀល** ដែលលោកទិញក្នុងតម្លៃ **៤០០ លានរៀល**។ លោកបានបង់ពន្ធប្រថាប់ត្រាលើអចលនទ្រព្យ **១៦ លានរៀល** បានចំណាយកម្រៃជើងសាសម្រាប់លក់ផ្ទះ **២៤ លានរៀល** និងចំណាយជួសជុល **២០ លានរៀល**។ លោក **ក** បានរក្សាទុកឯកសារចំណាយពាក់ព័ន្ធទាំងអស់។

- **គណនាថ្លៃដើមនៃទ្រព្យ**

  ថ្លៃដើម + ប្រាក់ពន្ធបានបង់ + ចំណាយកម្រៃជើងសា + ចំណាយកែលម្អ

  400 លាន + 16 លាន + 24 លាន +20 លាន= 460 លានរៀល

- **គណនាចំណេញមូលធន**

  ថ្លៃលក់ឬផ្ទេរទ្រព្យ - ថ្លៃដើមនៃទ្រព្យ

  600 លាន - 460 លាន = 140 លានរៀល

- **គណនាពន្ធលើចំណេញមូលធន**

  ចំណេញមូលធន X ២០%

  140 លាន x 20%= 28 លានរៀល




# ការលើកលែងពន្ធ

- ទ្រព្យដែលជាកម្មសិទ្ធិរបស់ស្ថាប័នរដ្ឋ
- ទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ ឬទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសនៃរដ្ឋាភិបាលដទៃ
- និវាសនដ្ឋានជាគោលដើមរបស់អ្នកជាប់ពន្ធ ដែលបានកាន់កាប់ក្នុងរយៈពេលយ៉ាងតិច ៥ ឆ្នាំមុនពេលលក់ឬផ្ទេរ។ ក្នុងករណីមាននិវាសនដ្ឋានច្រើនជាងមួយ ឬអ្នកជាប់ពន្ធនិងសហព័ទ្ធមាននិវាសនដ្ឋានផ្សេងពីគ្នា និវាសនដ្ឋានតែមួយប៉ុណ្ណោះដែលត្រូវបានអនុញ្ញាតជានិវាសនដ្ឋានគោលដើម។

# ការលើកលែងពន្ធ

- អចលនទ្រព្យក្នុងរង្វង់ញាតិដូចមានចែងក្នុងបទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រា វៀរលែងតែការផ្ទេរកម្មសិទ្ធិឬសិទ្ធិកាន់កាប់អចលនទ្រព្យរវាងបងប្អូនបង្កើតនិងបងប្អូនបង្កើត រវាងឪពុក-ម្តាយក្មេកនិងកូនប្រសារ នឹងរវាងយាយ-តាក្មេកនិងចៅប្រសារ។
- ទ្រព្យដែលត្រូវបានលក់ឬផ្ទេរដើម្បីប្រយោជន៍សាធារណៈ ស្របតាមច្បាប់អស្សាមិករណ៍។




# បញ្ហាប្រឈមក្នុងការអនុវត្តពន្ធលើចំណេញមូលធននៅតាមបណ្តាប្រទេសមួយចំនួន

តាមរយៈការសិក្សាស្រាវជ្រាវ និងការដកស្រង់បទពិសោធន៍ជាក់ស្តែងពីជំនាញការបរទេស ឃើញថា ក្នុងការអនុវត្តពន្ធលើចំណេញមូលធននៅតាមបណ្តាប្រទេសទាំងនោះមានជួបប្រទះបញ្ហាប្រឈមមួយចំនួននៅមុនពេល និងក្នុងពេលអនុវត្តការប្រមូលពន្ធលើចំណេញមូលធន ជារួម÷

- ការកំណត់តម្លៃលក់នៃអចលនទ្រព្យ
- ការកែសម្រួលអត្រាពន្ធចំពោះប្រភេទទ្រព្យមួយចំនួន
- ការរកនូវសន្ទស្សន៍អតិផរណា (Inflation Index) ដែលត្រឹមត្រូវនៃទ្រព្យ ក្នុងការគណនារកតម្លៃមូលដ្ឋាននៃការគិតពន្ធលើចំណេញមូលធន
- ការប្រកាសមិនពិតរបស់អ្នកជាប់ពន្ធពីថ្លៃដើមនៃការកែលំអទ្រព្យសម្បត្តិ (ដែលត្រូវកាត់ចេញពីតម្លៃលក់សម្រាប់គណនាចំណេញមូលធន)។




# បញ្ហាប្រឈម និងអត្ថប្រយោជន៍ក្នុងការអនុវត្តប្រមូលពន្ធលើចំណេញមូលធន ក្នុងបរិបទប្រទេសកម្ពុជា

អគ្គនាយកដ្ឋានពន្ធដារយល់ឃើញថានៅពេលអនុវត្ត CGT ដោយសារតែពន្ធលើចំណេញមូលធននេះ ផ្តោតជាសំខាន់លើរូបវន្តបុគ្គលដែលជា ប្រជាពលរដ្ឋទូទៅ ហេតុនេះ វាអាចមានបញ្ហាប្រឈមមួយចំនួននៅពេលយើងដាក់ឱ្យអនុវត្ត ដូចជា÷

- ការមិនសូវយល់ច្បាស់អំពីប្រភេទពន្ធនេះ
- ការយល់ដឹងមានកម្រិតរបស់អ្នកជាប់ពន្ធលើបែបបទនិងនីតិវិធីនៃការដាក់លិខិតប្រកាស




# ការរៀបចំផែនការផ្សព្វផ្សាយនិងណែនាំស្តីពីពន្ធលើចំណេញមូលធន

ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះ អពដ ផ្តោតសំខាន់លើការរៀបចំផែនការផ្សព្វផ្សាយ និងណែនាំបទប្បញ្ញត្តិស្តីពីពន្ធលើចំណេញមូលធន ឱ្យបានទូលំទូលាយដល់សាធារណជន និងអ្នកជាប់ពន្ធ មានជាអាទិ៍÷

- ផ្សព្វផ្សាយប្រកាសស្តីពីពន្ធលើចំណេញមូលធន តាមរយៈគេហទំព័រ (GDT Website) បណ្តាញទំនាក់ទំនងសង្គម (Facebook) នៃអគ្គនាយកដ្ឋានពន្ធដារ និងបណ្តាញព័ត៌មានផ្សេងៗ
- វីដេអូឃ្លីបពាក់ព័ន្ធនឹងការបង់ពន្ធលើចំណេញមូលធន
- ផ្សាយផ្ទាល់កម្មវិធីពន្ធដារ (GDT Live Show) ស្តីពីប្រកាសស្តីពីពន្ធលើចំណេញមូលធន និងវេទិកាសំណួរ-ចម្លើយតាមរយៈ Live Chat និង Call Center
- រៀបចំសេចក្តីណែនាំបន្ថែមស្តីពីការដាក់លិខិតប្រកាស និងបង់ពន្ធលើចំណេញមូលធន
- រៀបចំកម្មវិធីសិក្ខាសាលាជូនដល់អ្នកជាប់ពន្ធនៅតាមរាជធានី-ខេត្ត
- រៀបចំវគ្គបណ្តុះបណ្តាលជូនមន្ត្រីពន្ធដារនៅតាមរាជធានី-ខេត្ត
- បញ្ចូលមេរៀនស្តីពីពន្ធលើចំណេញមូលធនក្នុងកម្មវិធីវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈពន្ធដារ នៅសាលាជាតិពន្ធដារ។

# អត្ថប្រយោជន៍ក្នុងការអនុវត្តប្រមូលពន្ធលើចំណេញមូលធន

- ពន្ធលើចំណេញមូលធន នឹងចូលរួមចំណែកក្នុងការបង្កើនចំណូលថវិកាជាតិស្របតាមយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ ដើម្បីធានាបានចីរភាពនៃកំណើនចំណូល ចីរភាពនៃកំណើនសេដ្ឋកិច្ច ការប្រកួតប្រជែងដោយស្មើភាព និងសមធមិសង្គម

- ពន្ធនេះក៏ចូលរួមចំណែកក្នុងការទប់ស្កាត់រូបភាពនៃការចៀសវាងពន្ធតាមរយៈការទិញលក់អចលនទ្រព្យរបស់នីតិបុគ្គលក្នុងលក្ខណៈជារូបវន្តបុគ្គល ដើម្បីធានាសមភាពរវាងរូបវន្តបុគ្គល និងនីតិបុគ្គល ព្រមទាំងជំរុញការវិនិយោគ




# អត្ថប្រយោជន៍ក្នុងការអនុវត្តប្រមូលពន្ធលើចំណេញមូលធន

-ពន្ធនេះ ត្រូវបានចាត់ទុកថាជាវិធានការសារពើពន្ធរបស់រដ្ឋាភិបាលដើម្បីគ្រប់គ្រងសកម្មភាពបរិកប្បកម្មលើអចលនទ្រព្យ (To control real estate speculation) និងរក្សាស្ថិរភាពថ្លៃនៃអចលនទ្រព្យ

-ចំពោះអ្នកអភិវឌ្ឍន៍លំនៅដ្ឋានដែលបានចុះបញ្ជីជានីតិបុគ្គល និងបានបំពេញកាតព្វកិច្ចសារពើពន្ធរួចរាល់ហើយ គឺចំណេញមូលធនត្រូវបានគិតបញ្ចូលក្នុងប្រាក់ចំណូលជាប់ពន្ធក្នុងក្របខណ្ឌនៃពន្ធលើប្រាក់ចំណូលប្រចាំឆ្នាំ

- ការប្រមូលពន្ធនេះ ក៏មានការគិតគូរពីប្រជាពលរដ្ឋដែលមានអចលនទ្រព្យតិចតួច ដោយផ្តល់ការលើកលែងពន្ធចំពោះការលក់ ឬផ្ទេរនិវាសនដ្ឋានជាគោលដើម និងការផ្ទេរអចលនទ្រព្យក្នុងរង្វង់ញាតិ។


បើកប្រាក់ខែជូនមន្ត្រីរាជការ
To Pay Salary For Civil Servants
សាងសង់មន្ទីរពេទ្យ
To Build Hospitals
បើកប្រាក់ខែជូនយោធាពលនគរបាលប្រដាប់អាវុធ
To Pay Salary For Soldiers And Forces
សាងសង់ផ្លូវ
To Build Roads
TAXES
សាងសង់ស្ពាន
To Build Bridges
ការពារព្រំដែន
To Defend Borders & Heritages
សាងសង់សាលារៀន
To Build Schools

# សូមអរគុណ